# Living the Lotus 12

## Buddhism in Everyday Life

2025
VOL. 243



## 立正佼成会国際仏教教会（IBC）

### 心をつなぐ、在留外国人のための仏教コミュニティ





会員宅訪問



法座修行



生け花クラス



東京国立博物館見学



日本語クラス

**Living the Lotus**
**Vol. 243 (December 2025)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# យើងនាំគ្នាប្រគុំភ្លេងរមនាភាព ①

## តម្រូវការឱ្យមានការភ្ញាក់រលឹកនិងតួនាទី

ដោយព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## យើងទាំងឡាយមានភាពសុខដុមរមនារួចស្រេចទៅហើយ

"ដោយសារតែកោសិកាវាធ្វើការបណ្ដើរជួយកោសិកាផ្សេងទៀតបណ្ដើរសរីរាង្គ(ដូចជាសួត ក្រពះ ថ្លើម)របស់យើងក៏អាចមានដំណើរការបាន។ សរីរាង្គក៏ធ្វើការបណ្ដើរជួយសរីរាង្គផ្សេងៗទៀតបណ្ដើរដែរ" (Chi chi, ខែមករា 2011 )។ ទាំងនេះគឺជាពាក្យរបស់សាស្ត្រាចារ្យមូរ៉ាកាមី កាហ្ស៊ុអុ (Kazuo Murakami) សាស្ត្រាចារ្យ កិត្តិយស នៅសាកលវិទ្យាល័យទ្ស៊ឹគឹបា(Tsukuba)។

នៅលេខខែមុនខ្ញុំព្រះករុណាអាត្មាភាពបានលើកយកស្ថានភាពបច្ចុប្បន្ននៃពិភពលោកសព្វថ្ងៃមកគិតនិងចិត្តដែលធ្វើឲ្យមនុស្សនិងពិភពលោកបាត់បង់សណ្ដាប់ធ្នាប់និងភាពរមនាហើយនិងពីអ្វីដែលសំខាន់សម្រាប់យើងម្នាក់ៗក្នុងពេលឥឡូវនេះ។គឺថាប្រសិនបើយើងគិតទៅតាមលំដាប់កោសិកានៃរាងកាយរបស់យើងដែលនីមួយៗជួយគ្នាទៅវិញទៅមកភាពសុខដុមរមនានោះនឹងត្រូវបានរក្សាយ៉ាងធម្មតា។គឺថាយើងគ្រាន់តែធ្វើត្រាប់តាមកោសិកាយើងដោយប្រើការជួយគ្នាទៅវិញទៅមកប្រើប្រាស់ភាពសុខដុ មរមនាដែលមានស្រាប់ពីធម្មជាតិនោះ ឱ្យអស់ពីសមត្ថភាពតែប៉ុណ្ណោះ"សន្តិភាពពិភពលោកមិនមែនមិនអាចទៅរួចនោះទេ" ។ក៏ប៉ុន្តែយើងទាំងអស់គ្នាដឹងថានេះមិនមែនជាកិច្ចការងាយស្រួលឡើយ។

ទោះជាយ៉ាងណាក៏ដោយបើក្នុងចំណោមអ្វីដែលរៀបរាប់ខាងក្រោមនេះសូម្បីតែមួយក៏ដោយត្រូវបានរៀបចំឱ្យមានសណ្ដាប់ធ្នាប់មែននោះភាពសុខដុមរមនារបស់មនុស្សនិងសន្តិភាពពិភពលោកនឹងលែងជាសុបិនទៀតហើយ។

ប្រសិនបើមនុស្សម្នាក់ៗរស់នៅរាល់ថ្ងៃដោយការដឹងគុណ ហើយសមាជិកគ្រួសារទាំងអស់រស់នៅដោយសុខដុមរមនា វានឹងជះឥទ្ធិពលដល់អ្នកជិតខាងហើយមនុស្សក្នុងសហគមន៍នឹងរាប់អានស្រឡាញ់គ្នារអ្ហូករអឺន។ លើសពីនេះទៅទៀតនៅពេលដែលប្រទេសមានសុខសន្តិភាពនិងសន្តិសុខ ហើយប្រជាពលរដ្ឋគ្រប់ៗគ្នាអាចរស់នៅដោយមិនមានការព្រួយបារម្ភ ប្រទេសនោះនឹងត្រូវបានប្រទេសដទៃជឿទុកចិត្តហើយកសាងទំនាក់ទំនងប្រកបដោយភាពសុខដុមរមនាជាមួយគ្នា។

ពីមុនមកខ្ញុំព្រះករុណាអាត្មាភាពតែងតែលើកយកពាក្យរបស់ខុងជឺ(Confucius)ដែលនិយាយថា "កសាងខ្លួនឯង គ្រប់គ្រងគ្រួសារឱ្យបានល្អ គ្រប់គ្រងប្រទេសឱ្យបានសុខនឹងនាំមកនូវសន្តិភាពដល់ពិភពលោក" ហើយខ្ញុំព្រះករុណាអាត្មាភាពឱ្យតម្លៃជាពិសេសទៅលើ"ការគ្រប់គ្រងគ្រួសារឱ្យបានល្អ" ពី ព្រោះខ្ញុំព្រះករុណាអាត្មាភាពជឿថាបើកោ សិកាគ្រួសារមានសុខភាពល្អនឹងនាំទៅរកសន្តិភាពពិភពលោក។

ដែលខ្ញុំព្រះករុណាអាត្មាភាពគិតថាគ្រួសារជា "សំណាប" ដែរ នោះពីព្រោះខ្ញុំព្រះករុណាអាត្មាភាពជឿថា លុះត្រាតែសមាជិកគ្រួសារចុះសម្រុងគ្នា ទើបពួកគេអាចបណ្តុះបុគ្គលិកលក្ខណៈដែលយល់ពីមាគ៌ារបស់មនុស្សហើយមនុស្សដែលបានធំធាត់ឡើងតាមវិធីនេះនឹងនាំមកនូវផលជាផ្លែផ្កានៃសន្តិភាព។

## អត្ថន័យពិតនៃ "សេចក្ដីស្នេហាជាតិ"

ឥឡូវនេះ តើអ្នកម្នាក់ៗមានតួនាទីអ្វីខ្លះនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក នៅក្នុងគ្រួសារនៅក្នុងសហគមន៍ នៅសាលារៀន និងនៅកន្លែងធ្វើការ? តើអ្នកមានដឹងពីតួនាទីអ្នកថាការជួយអ្នកដទៃវាមានយន្តការដូចម្ដេចទេ? ហេតុផលដែលខ្ញុំព្រះករុណាអាត្មាភាពសួរសំណួរនេះ គឺដោយសារតែការធ្វើតាមគំរូនៃកោសិកានិងនៅពេលដែលបុគ្គលម្នាក់ៗបំពេញតួនាទីផ្ទាល់ខ្លួនរបស់ពួកគេគឺពួកគេកំពុងតែចូលរួមក្នុងសកម្មភាពដែលផ្ដល់ប្រយោជន៍ដល់ខ្លួនគេផងដល់អ្នកដទៃផងដែលនឹងនាំឱ្យភាពសុខដុមរមនាបានរក្សាគង់វង់។

ដូច្នេះហើយ ដើម្បីឲ្យមានភាពសុខដុមរមនាជាមួយនឹងអ្នកជុំវិញខ្លួននិងបង្កើតបទភ្លេងដ៏ពីរោះ អ្នកត្រូវដឹងពីចំណុចខ្លាំងនិងតួនាទីរបស់អ្នកជាមុនសិន រួចហើយខិតខំបំពេញតួនាទីនោះឱ្យអស់ពីសមត្ថភាព។ បន្ទាប់មកទៀតក្រៅពីស្ដាប់សម្លេងរបស់ខ្លួនឯងត្រូវផ្ទៀងត្រចៀកស្ដាប់សំឡេងនិងចិត្តរបស់អ្នកដទៃទៀតដែលជាសមាជិកនៃវង់តន្ត្រីដោយយកចិត្តទុកដាក់ផងដែរ។ ដើម្បីប្រើប្រាស់សមត្ថភាពរបស់ខ្លួនឱ្យបានពេញលេញមនុស្សម្នាក់ៗត្រូវគិតថាខ្លួនជាសមាជិកនៃវង់តន្ត្រីស៊ីមហ្វូនីផ្ទៀងត្រចៀកស្ដាប់សំឡេងនិងដួងចិត្តរបស់សមាជិកក្រុមភ្លេងទៅវិញទៅមកហើយខ្វល់ខ្វាយថាតើកម្រិតសំឡេងរបស់ខ្លួនឯងខ្លាំងពេកឬមិនច្បាស់ទេឬយ៉ាងណា។ បើធ្វើបែបនេះសម្លេងពីរោះដែលមានភាពសុខដុមរមនាធ្វើឱ្យមនុស្សគ្រប់គ្នាដែលមកស្ដាប់មានការស្ងប់ចិត្តនិងភាពកក់ក្ដៅនឹងកើតមានឡើង។

បន្ថែមពីលើនេះទ្រឹស្ដីរូបវិទ្យាវិទូលោកសាជី ហារឹអូ ( Saji Haruo ) បង្រៀនយើងថាមាន"ពាក្យដែលអាចជួយសង្គ្រោះសង្គមដែលច្របូកច្របល់បាន " ។ ប្រសិនបើមនុស្សគ្រប់គ្នាអាចនិយាយដោយស្មោះត្រង់បានបទនូវពាក្យថា "អរគុណ ដោយសារគុណបុណ្យអ្នក និងសុំទោស" បាននោះភាពសុខដុមរមនានឹងអាចនៅរក្សាបានយូរអង្វែង។

ព្រះស្ថាបនិកកៃសូសាម៉ាបានអះអាងបន្ថែមថា"ប្រជាជនលើពិភពលោកមិនអាចស្រឡា ញ់ជនជាតិមួយដែលមិនស្រឡាញ់ប្រទេសជាតិរបស់ខ្លួនពិតប្រាកដដោយចិត្តស្មោះអស់ពីពោះនោះទេ"។

ពោលគឺថាសេចក្ដីស្នេហាជាតិនៃប្រជាជនមានសារៈសំខាន់ណាស់សម្រាប់ភាពសុខ ដុមរមនាជាមួយប្រទេសដទៃ។ក៏ប៉ុន្តែនេះមិនមែនជាសេចក្ដីស្នេហាជាតិបែបជាតិនិយមឬអនុត្តរភាពនិយមធំប្រើកម្លាំងឈ្លានពានតូចហើយអាចឈានទៅដល់សង្គ្រាមបង្ហូរឈាមនោះទេ។គឺជាចិត្តដែលប្រាថ្នាចង់ធ្វើឲ្យប្រទេសជាតិមានសន្តិភាពពិតប្រាកដដោយសារតែចិត្តស្រឡាញ់ប្រទេសជាតិតែម្យ៉ាង។ គឺជាបេះដូងដែលចង់បន្សល់ទុកដល់កូនចៅជំនាន់ក្រោយនូវប្រទេសមួយដែលប្រជាជនអាចរស់នៅបានដោយសុខក្សេមក្សាន្ត។ជនជាតិនៃប្រទេសដទៃប្រសិនបើគេស្រឡាញ់ប្រទេសបែបនេះដូចគ្នាដែរ គេច្បាស់ជាមានចិត្តចុះសម្រុងគ្នានឹងយើងហើយសង្គ្រាមមិនអាចកើតឡើងបានឡើយ។

សេចក្ដីស្រឡាញ់ជាតិក៏គឺជាការគោរពចំ ពោះអ្នកដទៃផងហើយនៅពេលខ្លះជាការឆ្លុះបញ្ចាំងខ្លួនឯងដោយធ្វើស្វ័យត្រិះរិះហើយមានអារម្មណ៍ខ្មាសអៀនដែលអាចជាកម្លាំងជំរុញឲ្យមានការកែលម្អដែរ។

ខ្ញុំព្រះករុណាអាត្មាភាពសង្ឃឹមថាយើងម្នាក់ ៗនឹងមិនភ្លេចនូវមាគ៌ាជីវិតពិតរបស់មនុស្ស (មនុស្សធម៌ )ស្រឡាញ់ប្រទេសជាតិរបស់ខ្លួនហើយ ស្រឡាញ់អ្នកដទៃ ប្រើប្រាស់ខ្លួនឯងជាប្រទីបសម្រាប់បំភ្លឺខ្លួនឯងនិងយកព្រះធម៌ជាប្រទីបបំភ្លឺផ្លូវដើម្បីនាំមកនូវ"សេចក្ដីសុខដែលកើតចេញពីការចែករំលែកមិនមែនការឆក់ប្លន់ដណ្ដើមយកសុខតែឯង"បង្ហាញគំនិតនេះទៅកាន់ពិភពលោកហើយបញ្ជូនបន្តទៅមនុស្សជំនាន់ក្រោយទៀត។

From Kosei, December 2025




## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp